**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
******

**អន្តរក្រសួង**
**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**
**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ**

លេខ : ៤៣២ សហវ

ភ្នំពេញ , ថ្ងៃទី ១២ ខែ កក្កដា ឆ្នាំ ២០០២

# ប្រកាសអន្តរក្រសួង
# ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង
# ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
# ស្តីពី
# ការបង្កើតគណៈកម្មការអន្តរក្រសួងសំរាប់រៀបចំប្រព័ន្ធគ្រប់គ្រងចំណូលព្រៃឈើ

*****

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ ១៩៩៤ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត ១១៩៨.៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

-បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែមករា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៩/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

-បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

-បានឃើញច្បាប់អំពីប្រព័ន្ធហិរញ្ញវត្ថុដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ០១នស/៩៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣

-បានឃើញតំរូវការចាំបាច់របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ និង ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

**សំរេច**

**ប្រការ ១ :** បង្កើតគណៈកម្មការអន្តរក្រសួងសំរាប់រៀបចំប្រព័ន្ធគ្រប់គ្រងចំណូលព្រៃឈើ ដើម្បីពិនិត្យនិងរៀបចំឡើងវិញនូវប្រព័ន្ធចំណូលពីវិស័យព្រៃឈើកម្ពុជា ។

**ប្រការ ២ :** គណៈកម្មការរៀបចំប្រព័ន្ធគ្រប់គ្រងចំណូលព្រៃឈើមានសមាសភាពដូចខាងក្រោម :

- លោក ញឹប ច័ន្ទថេត ប្រធាននាយកដ្ឋានគណនេយ្យ ហិរញ្ញវត្ថុនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ជាប្រធាន
- លោក នេត មុន្នី អនុប្រធានទី ១ នាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជាអនុប្រធាន
- លោក ខួង ប៊ុននី អនុប្រធាននាយកដ្ឋានគណនេយ្យ ហិរញ្ញវត្ថុនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ជាសមាជិក
- លោក វណ្ណ សំណាង ប្រធានការិយាល័យនៃនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជាសមាជិក
- លោក ស៊ុំ សុខុន ប្រធានក្រុមត្រួតពិនិត្យហិរញ្ញវត្ថុអមក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ជាសមាជិក
- លោក ឆេង គឹមស៊ុន ប្រធានការិយាល័យកិច្ចការព្រៃឈើនៃនាយកដ្ឋាន រុក្ខា-ប្រមាញ់ ជាសមាជិក
- លោក ចន សារ៉ាត អនុប្រធានការិយាល័យផែនការ គណនេយ្យ នៃនាយកដ្ឋានរុក្ខា-ប្រមាញ់ ជាសមាជិក ។

**ប្រការ ៣ :** គណៈកម្មការរៀបចំប្រព័ន្ធគ្រប់គ្រងចំណូលព្រៃឈើមានភារកិច្ចពិនិត្យឡើងវិញនូវនីតិវិធី ក្នុងការប្រមូលចំណូលសួយសារឈើឈរ និង រាល់ចំណូលព្រៃឈើផ្សេងៗទៀត ព្រមទាំងនីតិវិធីដែលពាក់ព័ន្ធនឹងការគ្រប់គ្រងចំណូល ដូចជា ការរៀបចំផែនការ កត់ត្រាចំណូល ធ្វើរបាយការណ៍ ផ្សព្វផ្សាយ និង សវនកម្ម ជាដើម ។

**ប្រការ ៤ :** គណៈកម្មការអន្តរក្រសួងនេះ :

-ត្រូវរៀបចំទំរង់របាយការណ៍ជាស្តង់ដាជាភាសាខ្មែរ និង អង់គ្លេសនូវរាល់ប្រតិបត្តិការប្រចាំឆ្នាំអោយបានលំអិតស្តីពីការគ្រប់គ្រងចំណូលសួយសារ និង ចំណូលព្រៃឈើផ្សេងៗទៀត

-ត្រូវរៀបចំផែនការលំអិតសំរាប់ណែនាំស្តីពីនីតិវិធីដែលបានស្នើឡើង ក្នុងនោះរួមមាន ការប៉ាន់ស្មានលើតំរូវការ និង ផ្គត់ផ្គង់សំភារៈការិយាល័យ សំរាប់នាយកដ្ឋានរុក្ខា-ប្រមាញ់ និង ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។ កិច្ចការនេះត្រូវដាក់បញ្ចូលក្នុងផែនការលទ្ធកម្មរបស់គំរោងធនាគារពិភពលោក ដែលផ្តល់ហិរញ្ញប្បទាន សំរាប់ "គំរោងការគ្រប់គ្រង និង ត្រួតពិនិត្យព្រៃសម្បទានគំរូ"

-ត្រូវរៀបចំកម្មវិធីបណ្តុះបណ្តាល និង ផ្តល់ការយល់ដឹងសំរាប់មន្ត្រីនាយកដ្ឋានរុក្ខាប្រមាញ់ មន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និងបុគ្គលិកក្រុមហ៊ុនព្រៃសម្បទាន

-ត្រូវរៀបចំសេចក្តីព្រាងណែនាំដើម្បីអោយក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ផ្សព្វផ្សាយជាផ្លូវការនូវសំណើសុំរបស់គណៈកម្មការ និង អាចសុំការអនុម័តបន្ថែមទៀតចំពោះករណីចាំបាច់ (សុំការយល់ព្រមពីទីស្តីការគណៈរដ្ឋមន្ត្រី)

-ធ្វើការពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធ លើផ្នែកចាំបាច់មួយនៃការងាររបស់ខ្លួន ហើយត្រូវធ្វើរបាយការណ៍ ដាក់ជូនក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ត្រឹមថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០០២ ។

**ប្រការ ៥** : រាល់ការចំណាយលើការងាររបស់គណៈកម្មការនេះ នឹងត្រូវទូទាត់ចំណាយជាក្រោយ ពីគំរោងការគ្រប់គ្រង និង ត្រួតពិនិត្យព្រៃសម្បទានគំរូ ដែលហិរញ្ញប្បទានដោយធនាគារពិភពលោក ។

**ប្រការ ៦** : បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះត្រូវទុកជានិរាករណ៍ ។

**ប្រការ ៧** : ប្រធានគ្រប់អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ។

**ប្រការ ៨** : ប្រកាសនេះចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋមន្ត្រី
ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

គាត ឈន់

រដ្ឋមន្ត្រី
ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

ច័ន្ទ សារុន

ចម្លងជូន :
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងពាក់ព័ន្ធ
"ដើម្បីជូនជ្រាប"
- ដូចក្នុងប្រការ ៧ "ដើម្បីអនុវត្ត"
- ឯកសារ - កាលប្បវត្តិ